# រឿង មហាចោរនៅទល់ដែន

## ភាគទី៣៨ (ទារុណកម្ម)

រួចលោកមាក្នុងពេលបណ្ដើរនេះ សូមវាយវានឹងរំពាត់ផ្ដៅធំមួយ ឲ្យវាបែកឈាមហូរសស្រាក់ ឈឺចាប់ខ្លោចផ្សារ (មកដល់ពេលនេះកញ្ញានឹកថាពីព្រោះសេចក្ដីស្នេហារបស់នាងលើរូបបុរសនេះ ពុះពោរកញ្ជ្រោកកញ្ជ្រោលហូរសស្រាក់ឈឺចាប់ខ្លោចផ្សារដែរ) ចាំះ! រួចយកវាទៅ ចងផ្ដាងហាលថ្ងៃបង្អត់បាយបង្អត់ទឹក។ ធ្វើយ៉ាងនេះបានបីថ្ងៃ យកវាឲ្យទៅកិនស្រូវនឹងត្បាល់មួយធំវាយដំវាឲ្យប្រឹងៗឲ្យរួច។ សូមធ្វើយ៉ាងនេះអោយបានពីរខែ។ រួចរាល់ថ្ងៃអោយអ្នកស្រុកមកមើលវា ស្រែកចំអកឲ្យវាខ្មាស់គេ (នាងនឹកថា ព្រោះនាងបានខ្មាស បុរសនេះដូច្នោះឯង)។

ជនទាំងពីររូបក៏យល់ព្រម តាមកម្មវិធីរបស់នាងមណី។

មួយថ្ងៃក្រោយមកទៀត មានន្ទក៏ត្រូវទទួលទារុណកម្មដ៏ខ្លោចផ្សារបិត្តនេះ។ អ្នករងទុក្ខក្រៃណានឹងរកអ្វីផ្ទឹមស្មើគ្មាន។

ក្នុងពេលគេវាយបណ្ដើរអាក្រោស អ្នកស្រុកទាំងពួងផ្អើលឆោឡោទាំងចាស់ ទាំងក្មេងមកមើលយ៉ាងអ៊ូអរពាសពេញ។ អ្នកផងសំដែងសេចក្ដីអាណិត អ្នកផងជេរប្រទេសផ្ដាសាថែម។ ក្នុងពពួកអ្នកជួយស្អប់ យើងសង្កេតឃើញច្រើនតែពួកដែលរស់ជារណបនៅជើងកំផែងព្រះកម្ពុត រួចពីនោះគឺអ្នកមិនយល់ពីរឿងច្បាស់ ក្រោយបំផុត គឺពួកអ្នកមិនដឹងរឿងអ្វីសោះដែលមានត្រចៀកស្រាល ចេះតែជឿតាមគេ ឥតចេះគិតដល់តិចតួចឡើយ។

តែរឿងមានន្ទ ក៏បានផ្ទុះឮសុសសាយអាណាខេត្តសេរីសោភ័ណ។

អ្នកផង ទាំងខាងពួកស្អប់ ទាំងខាងពួកស្រលាញ់ អាណិត ស្គាល់មានន្ទគ្រប់គ្នាថាជា "មហាចោរនៅទល់ដែន"។

ថ្ងៃមួយ មានន្ទកំពុងធ្វើការអូសរទេះដែលផ្ទុកសុទ្ធតែថ្មកណ្ដាលថ្ងៃបែកញើសហូរហោម ក្រោមរំពាត់របស់កងយោធា នាងមណីកើតចិត្តមួយចង់ឃើញនឹងភ្នែកនូវទុក្ខវេទនារបស់មានន្ទ ដែលមានរូបនាងជាបុព្វហេតុ។

អត្ថបទដោយ៖ មាស សុភាព

ស្រីវរលក្ខណ៍បានដើរទៅលបមើលបុរសទុរគតនាកន្ទៃងមួយស្ងាត់កំបាំងពីភ្នែកអ្នកផង។ ធីតាអផ្សុកពេញខ្លួនទឹក ឃើញបុរសកាលណាក្តៅធ្លលក្នុងចិត្តកាលណោះ។

នាងចង់ឃើញ ព្រោះខ្លាចក្រែងមានន្ទមិនបានទទួលឲ្យសមតាមកម្មដែលស្រីទទួលដោយសារបុរសនេះ។ មណីហៅអស់ទាំងរូបកាយដោយទឹកមិនយល់ថា ប្រុសអ្វីក៏មាត់រឹងម្ទេះ។ ចិត្តនេះហាក់ដូចកៅស៊ូ ដែលធីតាប្រឹងទាញៗយ៉ាងពេញទំហឹងរួចដល់ពេលលែងវិញកៅស៊ូធួរមកដដែលដូចដើម។

មិនយូរប៉ុន្មាននាងឃើញមានន្ទធ្វើការ។ ក្នុងហ្វូងអ្នកមានទោសស្រីអង្កេតឃើញនាយកោបអគ្គី មហាកាល និងមនុស្សទោសឯទៀតនាងពុំស្គាល់។ អគ្គី មហាកាល និងនាយកោបខំត្រដេបត្រដាប ទាញរទេះដួលចុះដួលឡើង ដោយអស់កម្លាំងខ្លាំងពេក។ អ្នកយាមដែលមាននាទីចាំ តែត្រួតមើលការ ស្ទុះទៅវាយដំជនទាំងបីខ្ទាប់ៗ គ្មានត្រាប្រណី។

មានន្ទឈប់អូសរទេះខ្លួនមកចាប់សហការីទាំងបីលើកឡើង ដោយករុណា។

កោបនិយាយថា:

សុំទឹក! សុំទឹក!

មានន្ទស្ទុះទៅយកទឹកមួយត្រឡោកដែលនៅជិតនោះ ក្នុងពាងមួយអ្នកយាមម្នាក់វាយត្រឡោកធ្លាក់ពីដៃមានន្ទ! មាណពក្តៅក្នុងចិត្តជាពន់ពេក នឹកថាមួយពេលនេះស្លាប់ទៅល្អជាង។

អ្នកសំលឹងអ្នកយាមនោះ រួចស្ទុះភ្លៃតដាល់ផ្ទង។

អ្នកទោសឯទៀត ក៏កើតកាន់ជើងមានន្ទគ្គិលឡើងៗ

ការវាយប្រឡូកក៏កើតមានយ៉ាងជ្រួលច្រាលតែពួកមានន្ទដែលមានតែដៃទទេ ត្រូវពួកខាងតម្រួតវាយដួលក្រឡាប់ ផ្កាប់ផ្ការ។ មានមណីជាសាក្សីនៃរឿងនេះ។ ស្រីរំជួលក្នុងចិត្តត្បិតក្នុងសមុទ្រទុក្ខដែលនាងបានបង្កើតដោយចេតនាសង់សឹកនេះ មានន្ទបញ្ចេញនូវរស្មីមេត្តាមួយដែលដាស់អស់សតិសម្បជញ្ញៈស្រីឲ្យមានរស់ជាតិជូរចត់ក្រៃពេក។

កាមាស្ទុះភ្លៃតចេញពីពន្ធាជ័យមួយក្នុងបរិវេណទារុណកម្មនេះ។ មណីឃើញកាមាក៏រង់ចាំមើលហេតុការណ៍យ៉ាងណាទៅទៀត។

កាមបញ្ជាឲ្យពួកដែលកំពុងប្រឡូកគ្នានោះឈប់។

អត្ថបទដោយ៖ មាស សុភាព

អ្នកណាជាមេបះបោរក្នុងទីនេះ?
មានន្ទុឈរនៅស្ងៀមឥតចេញវាចារមួយម៉ាត់។
នាយតម្រួតម្នាក់ចង្អុលទៅមានន្ទុ:
នុ៎ះព្រះតេជគុណ វានោះជាមេបះបោរ!
កាមាដើរទៅជិតមានន្ទុដោយបញ្ចេញនូវអាការៈសាហាវមួយដែលរកអ្វីប្រដូចគ្មាន។
ហ៊ឺះ! បង! ជាប់ទោសហើយនៅបង្កកល្ងិយុគអីទៀត កាមាយារកំណាត់ឈើបំរុងវាយមានន្ទុ។
នាងមណីស្រែកយ៉ៃឡើងពីកន្លែងដែលពួន ត្បិតនាងទ្រាំមិនបាននឹងអំពើលាមកនេះ។

សម្រែកនេះ ធ្វើឲ្យអ្នកទោស ទាំងអ្នកប្រើអំណាច ឈប់ស្ងៀមស្រឡាំងកាំងមុខបែរទៅរកទីដែលសម្រែកហែកចេញមក។

(សូមរង់ចាំតាមដានភាគទី៣៩ នៅសប្តាហ៍ក្រោយ)

អត្ថបទដោយ៖ មាស សុភាព